ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)
លេខ៖ ០៩៧/២១ គ.វ.ក-១៩

ថ្ងៃ អង្គារ ៩កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្ថែមទីតាំងចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ ក្នុងខណ្ឌមួយចំនួននៃរាជធានីភ្នំពេញ អំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីសម្រួលដល់ការមកទទួលការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ និងធានាឱ្យបាននូវការរក្សាគម្លាតបុគ្គលស្របតាមវិធានការសុខាភិបាល គ.វ.ក-១៩ សម្រេចបន្ថែមទីតាំងចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ ក្នុងខណ្ឌចំនួន៥បន្ថែមទៀត៖

| ល.រ. | ខណ្ឌ | ទីតាំងចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ (Sinovac) ដូសទី២ |
|---|---|---|
| ១ | **ដូនពេញ (បន្ថែម១ទីតាំង)** | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>– សាលាបឋមសិក្សាកុលាប ១ (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– សណ្ឋាគារកាំបូឌីយ៉ាណា (រៀបចំដោយ ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប) (ទីតាំងថ្មី) |
| ២ | **ទួលគោក (បន្ថែម១ទីតាំង)** | – វិទ្យាល័យជាស៊ីម-សន្ធរម៉ុក ចំនួន ២ទីតាំង (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– សាលាបឋមសិក្សាបឹងសាឡាង ផ្លូវ៤៣០ កែងផ្លូវ២១៧(មុន្នីរ៉េត) ភូមិ១៦ សង្កាត់បឹងសាឡាង(រៀបចំដោយរដ្ឋបាលខណ្ឌទួលគោក) (ទីតាំងថ្មី) (តំបន់ក្រហម) |
| ៣ | **សែនសុខ (បន្ថែម១ទីតាំង)** | – ក្រសួងពាណិជ្ជកម្ម (រៀបចំដោយក្រសួងពាណិជ្ជកម្ម)<br>– សាលាបឋមសិក្សាភ្នំពេញថ្មី (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– ទីស្នាក់ការនៃគណៈមេធាវីកម្ពុជា ស្ថិតនៅសង្កាត់ភ្នំពេញថ្មី (រៀបចំដោយ គណៈមេធាវីកម្ពុជា) (ទីតាំងថ្មី) |
| ៤ | **ពោធិ៍សែនជ័យ (បន្ថែម១ទីតាំង)** | – សាលាបឋមសិក្សាតាំងកសាង (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា)<br>– អគ្គនាយកដ្ឋានប្រេងកាតនៅផ្លូវសហព័ន្ធរុស្ស៊ី (រៀបចំដោយក្រសួងរ៉ែ និងថាមពល)<br>– ស្តុបទួលពង្រ សង្កាត់ចោមចៅទី១ (រៀបចំដោយរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ) (ទីតាំងថ្មី) (តំបន់ក្រហម) |



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | |
|---|---|---|
| ៥ | **មានជ័យ (បន្ថែម១ទីតាំង)** | – បុរីជីបម៉ុង ផ្លូវ ៦០ម (រៀបចំដោយក្រុមហ៊ុនជីបម៉ុងគ្រុប)<br>– សាលាបឋមសិក្សាចាក់អង្រែលើ (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា)<br>– សាលាបឋមសិក្សាភូមិឬស្សី ស្ថិតនៅសង្កាត់ស្ទឹងមានជ័យទី២ (រៀបចំដោយរដ្ឋបាលខណ្ឌមានជ័យ) (ទីតាំងថ្មី)(តំបន់ក្រហម) |
| ***សំគាល់៖ ចំពោះការចាក់វ៉ាក់សាំងស៊ីណូហ្វាម និងស៊ីណូវ៉ាក់ដូសទី២ អាចចាក់អំឡុងពេល១៤ ទៅ២៨ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី១។*** | | |

ចំពោះទីតាំងបន្ថែមថ្មីនឹងចាប់ផ្តើមបើកដំណើរការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ដូចខាងក្រោម៖

- ទីតាំងស្ថិតនៅស្នាក់ការនៃគណៈមេធាវីកម្ពុជា និងសណ្ឋាគារកាំបូឌីយ៉ាណានឹងចាប់ផ្តើមពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១។
- ទីតាំងសាលាបឋមសិក្សាភូមិឬស្សីនឹងចាប់ផ្តើមពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១។
- ទីតាំងស្តុបទូលពង្រនឹងចាប់ផ្តើមពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១។
- ទីតាំងស្ថិតនៅសាលាបឋមសិក្សាបឹងសាឡាងនឹងបើកចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ រយៈពេល២ថ្ងៃ គឺថ្ងៃទី២២ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។

អាស្រ័យហេតុនេះ សូមបុគ្គលដែលដល់វេនចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ ហើយកំពុងរស់នៅក្នុងខណ្ឌទាំង៥ខាងលើអាចទៅចាក់វ៉ាកសាំងស៊ីណូវ៉ាក់ នៅទីតាំងដូចបានជម្រាបជូនខាងលើក្នុងខណ្ឌដែលបុគ្គលកំពុងរស់នៅ **ដោយមិនត្រូវឆ្លងខណ្ឌជាដាច់។**

**រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)**

វេជ្ជ. ឱ វណ្ណឌីន